ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

# សេចក្តីប្រកាសព័ត៌មាន
# សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យបញ្ជូនដីកាបញ្ជូនរឿងទៅអង្គជំនុំជម្រះសាលាដំបូង

## សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក-ការិយាល័យ

ថ្ងៃនេះ សហចៅក្រមស៊ើបអង្កេត រួមគ្នាបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាកាលពីថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ កន្លងទៅ។

ជាពិសេសសហចៅក្រមស៊ើបអង្កេត បានបដិសេធអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ចៅក្រមអង្គបុរេជំនុំជម្រះទាំងប្រាំរូប បានឯកភាពថា ដីកាបញ្ជូនទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសុពលភាព ដូចនេះ ជាឯកច្ឆ័ន្ទ សំណុំរឿងអាចត្រូវបានបញ្ជូនទៅជំនុំជម្រះ។ ជាការពិត ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានបង្ហាញជំហរផ្ទុយយ៉ាងជាក់លាក់ ដោយបញ្ជាឲ្យតម្កល់សំណុំរឿងក្នុងបណ្ណសារ។ ដូចនេះ ការគ្រាន់តែយោងលើពាក្យពេចន៍ ដែលត្រូវបានប្រើប្រាស់ របស់ចៅក្រមជាតិ មិនត្រូវនឹងខ្លឹមសារទេ។

ក្នុងពេលប្រើប្រាស់យុត្តាធិការមានកម្រិត ក្រោយពីមានសេចក្តីពិចារណា របស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ដែលត្រូវបានចេញក្នុងថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ សហចៅក្រមស៊ើបអង្កេតសូមបដិសេធការចោទប្រកាន់មួលបង្កាច់ដដែលៗ ដែលថា សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្ត ចេញពីចេតនាមិនល្អ ក្នុងការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា និង ជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតី។

សហចៅក្រមស៊ើបអង្កេតទាំងពីរ សូមបដិសេធផងដែរ ជាលម្អិតនូវការចោទប្រកាន់ថា ការមិនបានស្នើឲ្យអង្គបុរេជំនុំជម្រះពិចារណាការខ្វែងយោបល់ស្តីពីយុត្តាធិការបុគ្គល សហចៅក្រមស៊ើបអង្កេតបានព្យាយាមងាកពីយន្តការដោះស្រាយជម្លោះដោយអង្គបុរេជំនុំជម្រះ ហើយ បានបំពានក្របខ័ណ្ឌច្បាប់ អ.វ.ត.ក.។

ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេត មានក្តីបារម្ភថា ទោះបីជា បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលនៅពេលសម្រេចបញ្ចប់សំណុំរឿង ០០៤/២ ក្នុងថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ បានរកឃើញថា អង្គបុរេជំនុំជម្រះ គួរបញ្ចប់សំណុំរឿងដោយខ្លួនឯង យ៉ាងណាក្តី សំណុំរឿង ០០៣ នៅតែស្ថិតក្នុងហានីយភ័យដូចគ្នា

នៃភាពជាប់គាំង ដែលនាំឲ្យបំពានសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវ ការបញ្ចប់សំណុំរឿងជាស្ថាពរ និងឆាប់រហ័ស។

សេចក្តីសម្រេចទាំងស្រុង អាចរកបាននៅ៖

https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D270_7_KH.pdf